# សន្ធិសញ្ញា

# ស្តីពី

# ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់

# ក្នុងវិស័យព្រហ្មទណ្ឌ

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# សាធារណរដ្ឋសង្គមនិយមវៀតណាម

# សន្ធិសញ្ញា
# ស្តីពី
# ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
# រវាង
# ព្រះរាជាណាចក្រកម្ពុជា
# និង
# សាធារណរដ្ឋសង្គមនិយមវៀតណាម

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅនេះហៅថា "ភាគី")

ដោយមានបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការ សំដៅប្រយុទ្ធប្រឆាំងនឹងបទល្មើសប្រកបដោយប្រសិទ្ធភាព

ដោយឈរលើមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស វិធានច្បាប់ អធិបតេយ្យភាព សមភាព និងផលប្រយោជន៍ទាំងសងខាង

បានព្រមព្រៀងគ្នាដូចតទៅ ៖

## មាត្រា ១
## វិសាលភាពនៃការជួយគ្នាទៅវិញទៅមក

១.អនុលោមតាមសន្ធិសញ្ញា និងច្បាប់ជាតិរបស់ខ្លួន ភាគីត្រូវផ្តល់ជំនួយទៅវិញទៅមកផ្នែកច្បាប់ឱ្យបានជាអតិបរមាក្នុងវិស័យព្រហ្មទណ្ឌ ។

២.ជំនួយទៅវិញទៅមក ដែលត្រូវផ្តល់រួមមាន ៖

ក.សេវាកម្មឯកសារ ។

ខ.ការកោះហៅសាក្សី ឬ អ្នកជំនាញ ។

គ.ការប្រមូល និងការផ្តល់ភស្តុតាង ។

ឃ.ការផ្ទេរកិច្ចដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌ។

ង.ការផ្ទេរជាបណ្តោះអាសន្ននូវទណ្ឌិត ដែលកំពុងអនុវត្តទោសដាក់ពន្ធនាគារនៅក្នុងដែនដីនៃភាគីទទួលសំណើឲ្យមានវត្តមាននៅក្នុងដែនដីនៃភាគីផ្ញើសំណើ ដើម្បីជួយក្នុងការស៊ើបអង្កេត ឬផ្តល់ភស្តុតាង ។

ច.ការចាត់វិធានការនានាដើម្បីស្វែងរក កត់ត្រា រឹតត្បិតការចាត់ចែង បង្កក ចាប់យក ឬរឹបអូស ទ្រព្យដែលជាផលនៃបទល្មើស និង/ឬឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស ។



5

៥

ធ.ការផ្លាស់ប្តូរព័ត៌មាន ។

ជ.ទម្រង់ដទៃផ្សេងទៀតនៃជំនួយ ស្របតាមគោលបំណងនៃសន្ធិសញ្ញានេះ និង ដែលមិនផ្ទុយជាមួយនឹងច្បាប់នៃភាគីទទួលសំណើ។

## មាត្រា ២
## ការមិនអនុវត្តសន្ធិសញ្ញានេះ

១.សន្ធិសញ្ញានេះ មិនអនុវត្តចំពោះ ៖

ក.ការធ្វើបត្យាប័ន ឬការចាប់ខ្លួន ឬការឃុំខ្លួនបុគ្គលណាមួយ ក្នុងគោលបំណងនៃការធ្វើបត្យាប័នបុគ្គលនោះ ។

ខ.ការអនុវត្តសាលក្រមព្រហ្មទណ្ឌរបស់ភាគីធ្វើសំណើលើដែនដីនៃភាគីទទួលសំណើ លើកលែងករណីដែលច្បាប់នៃភាគីទទួលសំណើ និងសន្ធិសញ្ញានេះអនុញ្ញាត ។

គ.ការបញ្ជូនទណ្ឌិតដែលកំពុងអនុវត្តទោសដាក់ពន្ធនាគារ ដើម្បីបន្តការអនុវត្តទោសនេះ។

២.សន្ធិសញ្ញានេះ មិនផ្តល់សិទ្ធិឱ្យភាគីណាមួយ អនុវត្តនៅក្នុងដែនដីនៃភាគីម្ខាងទៀតនូវយុត្តាធិការ និងការបំពេញមុខងារ ដែលជាសិទ្ធិផ្តាច់មុខរបស់អាជ្ញាធរមានសមត្ថកិច្ចតាមច្បាប់ជាតិនៃភាគីម្ខាងទៀតឡើយ។

## មាត្រា ៣
## ការបដិសេធ ឬការផ្អាកនូវជំនួយ

១.ការផ្តល់ជំនួយ ត្រូវបានបដិសេធតាមសន្ធិសញ្ញានេះ ក្នុងករណីណាមួយដូចខាងក្រោម ៖

ក.សំណើសុំជំនួយ ដែលមិនស្របតាមកិច្ចព្រមព្រៀងអន្តរជាតិដែលភាគីទទួលសំណើជាសមាជិក ឬមិនស្របតាមច្បាប់នៃភាគីទទួលសំណើ ។

ខ.សំណើសុំជំនួយ អាចបង្កការអន្តរាយដល់អធិបតេយ្យភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬ ផលប្រយោជន៍ជាសារវន្តនៃភាគីទទួលសំណើ ។

គ.សំណើទាក់ទងនឹងការចោទប្រកាន់បុគ្គលណាមួយពីបទល្មើស ដែលបុគ្គលនោះត្រូវបានសម្រេចដាក់ឱ្យជាប់ទោស សម្រេចឲ្យរួចខ្លួនជាស្ថាពរ ឬ ត្រូវបានលើកលែងទោសក្នុងដែនដីនៃភាគីទទួលសំណើ ។

ឃ.សំណើសុំជំនួយដែលទាក់ទងនឹងបទល្មើស ដែលមិនត្រូវបានចោទប្រកាន់ដោយមូលហេតុនៃការផុតអាជ្ញាយុកាល ដោយអនុលោមតាមច្បាប់នៃភាគីទទួលសំណើ ។

ង.សំណើសុំជំនួយទាក់ទងនឹងអំពើសកម្ម ឬ អកម្ម ដែលមិនបានបង្កើតជាបទល្មើស



5 ᠘

ដោយអនុលោមតាមច្បាប់នៃភាគីទទួលសំណើ ។

២.ភាគីទទួលសំណើ អាចបដិសេធសំណើសុំជំនួយក្នុងករណីដូចខាងក្រោម៖

ក.សំណើសុំជំនួយចំពោះបទល្មើសដែលមានលក្ខណៈនយោបាយ។ ក្នុងករណីនេះ បទល្មើសភេរវកម្ម និងបទល្មើសដទៃផ្សេងទៀតដែលភាគីទទួលសំណើ អាចពិចារណាថា មិនមែនជាបទល្មើសដែលមានលក្ខណៈនយោបាយទេ ដោយផ្អែកតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលខ្លួនជាភាគី មិនទទួលស្គាល់ថាជា "បទល្មើសដែលមានលក្ខណៈនយោបាយ" ។

ខ.សំណើសុំជំនួយ ចំពោះបទល្មើសយោធា ដែលមិនមែនជាបទល្មើសចែងក្នុង ច្បាប់ព្រហ្មទណ្ឌសាមញ្ញ ។

គ.មានសំអាងគ្រប់គ្រាន់ដែលគួរឲ្យជឿបានថា សំណើសុំជំនួយមានលក្ខណៈ លំអៀង ចំពោះជនណាមួយដោយសារតែពូជសាសន៍ សាសនា ភេទ ជាតិពន្ធុ ជនជាតិ សញ្ជាតិ ឬទស្សនៈនយោបាយរបស់ជននោះ ។

៣.ភាគីទទួលសំណើ អាចផ្អាកជំនួយប្រសិនបើការអនុវត្តសំណើសុំជំនួយរាំងដល់ការ ស៊ើបអង្កេត ការចោទប្រកាន់ នីតិវិធីតុលាការដែលកំពុងដំណើរការ ឬការអនុវត្តសាលក្រម នៅក្នុងដែនដីនៃភាគីទទួលសំណើ។

៤.មុនពេលបដិសេធសំណើសុំជំនួយ ឬ ផ្អាកការអនុវត្តសំណើសុំជំនួយដោយអនុលោមតាម មាត្រានេះ ភាគីទទួលសំណើត្រូវ ៖

ក.ផ្តល់ព័ត៌មានជាបន្ទាន់ដល់ភាគីផ្ញើសំណើអំពីមូលហេតុនៃការបដិសេធ ឬការផ្អាក និង

ខ.ពិគ្រោះយោបល់ជាមួយភាគីផ្ញើសំណើ ដើម្បីកំណត់លទ្ធភាពអនុវត្តជំនួយ ជាមួយ បណ្តាលក្ខខណ្ឌ ដែលភាគីទទួលសំណើយល់ឃើញថាចាំបាច់ ។

៥.ប្រសិនបើភាគីផ្ញើសំណើទទួលយកជំនួយ ជាមួយនឹងលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ ទី៤ ចំនុច "ខ" នៃមាត្រានេះ ភាគីផ្ញើសំណើ ត្រូវប្រតិបត្តិតាមលក្ខខណ្ឌនោះ ។

## មាត្រា ៤

## អាជ្ញាធរកណ្តាល

១.ភាគីនីមួយៗ ត្រូវបង្កើតអាជ្ញាធរកណ្តាល ក្នុងគោលបំណងអនុវត្តសន្ធិសញ្ញានេះ។

២.ស្ថាប័នខាងក្រោមនេះ ត្រូវបានបង្កើតជាអាជ្ញាធរកណ្តាលពេលសន្ធិសញ្ញានេះចូលជា ធរមាន៖

ក.សម្រាប់ព្រះរាជាណាចក្រកម្ពុជា គឺក្រសួងយុត្តិធម៌។

ខ.សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម គឺអយ្យការប្រជាជនកំពូល។

៣.ភាគីនីមួយៗ ត្រូវផ្តល់ព័ត៌មានឲ្យគ្នាអំពីការផ្លាស់ប្តូរអាជ្ញាធរកណ្តាលរបស់ខ្លួន ដូច

មានចែងក្នុងកថាខណ្ឌទី២ នៃមាត្រានេះ។

៤.អាជ្ញាធរកណ្តាលត្រូវទំនាក់ទំនងគ្នាដោយផ្ទាល់ដើម្បីអនុវត្តសន្ធិសញ្ញានេះ ប៉ុន្តែគូភាគីអាចជ្រើសរើសទំនាក់ទំនងគ្នាតាមរយៈបណ្តាញការទូត។

## មាត្រា ៥
## ខ្លឹមសារនិងទម្រង់នៃសំណើសុំជំនួយ

១.លិខិតស្នើសុំជំនួយត្រូវមាន ៖

ក.ឈ្មោះ និងអាសយដ្ឋានការិយាល័យដែលបង្កើតសំណើសុំជំនួយ ។

ខ.ឈ្មោះ និងអាសយដ្ឋានការិយាល័យ ឬទីស្នាក់ការកណ្តាលរបស់ការិយាល័យទទួលសំណើ ។

គ.គោត្តនាម នាម និងអាសយដ្ឋានអចិន្ត្រៃយ៍ ឬការិយាល័យរបស់រូបវន្តបុគ្គល ឈ្មោះនិងអាសយដ្ឋានរបស់នីតិបុគ្គល ស្ថាប័ន ឬទីស្នាក់ការកណ្តាលរបស់នីតិបុគ្គល ឬស្ថាប័នដែលទាក់ទងនឹងសំណើសុំជំនួយ ។

ឃ.ខ្លឹមសារនៃជំនួយ គោលបំណងនៃសំណើសុំជំនួយ ប្រភេទ និងអង្គហេតុដែលពាក់ព័ន្ធទៅនឹងរឿងក្តី ការចង្អុលបង្ហាញមាត្រាច្បាប់ និងទណ្ឌកម្មដែលអាចត្រូវបានអនុវត្ត ការវិវត្តនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការ និងរយៈពេលកំណត់សម្រាប់ការអនុវត្តសំណើសុំជំនួយ។

២.លិខិតនៃសំណើសុំជំនួយអាចរួមមាន៖

ក.អត្តសញ្ញាណ សញ្ជាតិ និងទីកន្លែងស្នាក់នៅនៃបុគ្គលដែលជាកម្មវត្ថុនៃរឿងក្តី ឬបុគ្គលផ្សេងទៀតដែលដឹងពីព័ត៌មានទាក់ទងនឹងរឿងក្តីនេះ ។

ខ.បញ្ហាដែលត្រូវការយកចម្លើយ បញ្ជីសំណួរដែលត្រូវបានលើកឡើង និងប្រសិនបើមានសំណើសុំឱ្យប្រមូលភស្តុតាង ត្រូវអធិប្បាយអំពីឯកសារនានា កំណត់ហេតុ ឬវត្ថុតាងដែលត្រូវប្រគល់ ហើយប្រសិនបើចាំបាច់ពណ៌នាអំពីកិនភាគ និងអត្តសញ្ញាណបុគ្គលដែលតម្រូវឱ្យប្រគល់នូវឯកសារ កំណត់ហេតុ ឬវត្ថុតាងទាំងនោះ ។

គ.អត្ថន័យនៃកិច្ចការ បញ្ជីសំនួរនិងតម្រូវការចំពោះសាក្សី ឬអ្នកជំនាញ ដែលត្រូវបានកោះហៅ ។

ឃ.ចំពោះសំណើស្តីពីការឆែកឆេរ ការចាប់យក ឬស្វែងរក រឹបអូសទ្រព្យដែលជាផលនៃបទល្មើស និង/ឬ ឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើស ត្រូវពណ៌នាអំពីទ្រព្យ និងទីកន្លែងដែលមានទ្រព្យកំពុងស្វែងរក សំអាងដើម្បីកំណត់ទ្រព្យដែលជាផលនៃបទល្មើស និង/ឬ ឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើសកំពុងឋិតនៅលើដែនដីនៃភាគីទទួលសំណើ និងអាចឋិតក្រោម

យុត្តាធិការនៃភាគីធ្វើសំណើ និងការអនុវត្តសាលក្រម ឬសេចក្តីបង្គាប់របស់តុលាការ។

ង.វិធានការអនុវត្តចំពោះសំណើសុំជំនួយ ដែលអាចឈានទៅដល់ការរកឃើញ និង ការចាប់យកទ្រព្យដែលជាផលនៃបទល្មើស និង/ឬ ឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើស ។

ច.តម្រូវការ និងសេចក្តីលម្អិតនៃនីតិវិធីពិសេសណាមួយ ដែលភាគីធ្វើសំណើចង់ឲ្យអនុវត្តដើម្បីសម្រួលក្នុងការអនុវត្តសំណើសុំជំនួយ រួមមាន ទម្រង់ ឬ វិធីសាស្ត្រនៃការផ្តល់ព័ត៌មាន ភស្តុតាង ឯកសារ ឬវត្ថុជាអាទិ៍ ។

ឆ.តម្រូវការពិសេសនៃការរក្សាការសម្ងាត់ និងមូលហេតុ ។

ជ.គោលបំណង កាលបរិច្ឆេទ និងកាលវិភាគនៃការធ្វើដំណើរ ប្រសិនបើមន្ត្រីមានសមត្ថកិច្ចនៃភាគីធ្វើសំណើមានបំណងធ្វើដំណើរទៅកាន់ដែនដីនៃភាគីទទួលសំណើ ក្នុងគោលបំណងអនុវត្តសំណើសុំជំនួយ ។

ឈ.សាលក្រម ឬសេចក្តីសម្រេចព្រហ្មទណ្ឌរបស់តុលាការ និងឯកសារផ្សេងទៀត វត្ថុតាង ឬព័ត៌មានចាំបាច់សម្រាប់ការអនុវត្តសំណើសុំជំនួយ។

៣.ប្រសិនបើភាគីទទួលសំណើពិនិត្យឃើញថា ព័ត៌មាននៅក្នុងសំណើសុំជំនួយមិនគ្រប់គ្រាន់ដើម្បីអនុវត្តសំណើសុំជំនួយដោយអនុលោមតាមសន្ធិសញ្ញានេះ ភាគីទទួលសំណើ ត្រូវស្នើសុំព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរ និងកំណត់កាលបរិច្ឆេទជាក់លាក់ដើម្បីឲ្យភាគីធ្វើសំណើឆ្លើយតបនឹងសំណើសុំព័ត៌មានបន្ថែមនេះ។

៤.សំណើសុំជំនួយត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែក្នុងករណីបន្ទាន់និងមានការអនុញ្ញាតពីភាគីទទួលសំណើ ភាគីធ្វើសំណើអាចអនុវត្តតាមវិធីផ្សេងទៀត ប៉ុន្តែត្រូវជូនព័ត៌មានភ្លាមៗជាលាយលក្ខណ៍អក្សរតាមក្រោយ។

៥.លិខិតស្នើសុំនិងឯកសារភ្ជាប់មកជាមួយ ត្រូវធ្វើជាភាសារបស់ភាគីធ្វើសំណើ និងត្រូវភ្ជាប់មកជាមួយឯកសារបកប្រែជាភាសារបស់ភាគីទទួលសំណើឬ ភាសាផ្សេងទៀតដែលភាគីទទួលសំណើអាចទទួលយកបាន។

## មាត្រា ៦
## ការអនុវត្តសំណើសុំជំនួយ

១.សំណើសុំជំនួយត្រូវអនុវត្ត ស្របតាមច្បាប់និងវិធីអនុវត្តរបស់ភាគីទទួលសំណើ។ ភាគីទទួលសំណើត្រូវអនុវត្តសំណើសុំជំនួយ តាមវិធីជាក់លាក់ដែលបានកំណត់ដោយភាគីធ្វើសំណើ ប្រសិនបើសំណើសុំជំនួយនោះស្របតាមច្បាប់ និងវិធីអនុវត្តរបស់ភាគីទទួលសំណើ ។

២.ភាគីទទួលសំណើត្រូវជូនព័ត៌មានដល់ភាគីធ្វើសំណើអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការអនុវត្តសំណើសុំជំនួយប្រសិនបើមានការស្នើសុំ។



5 ✓

៣.ភាគីទទួលសំណើត្រូវជូនព័ត៌មានជាបន្ទាន់ដល់ភាគីផ្ញើសំណើ អំពីស្ថានការណ៍ដែលអាចនាំឲ្យមានការពន្យារពេលអនុវត្តសំណើសុំជំនួយ។

៤.អាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ ត្រូវជូនព័ត៌មានជាបន្ទាន់ដល់អាជ្ញាធរកណ្តាលនៃភាគីផ្ញើសំណើអំពីលទ្ធផលនៃការអនុវត្តសំណើសុំជំនួយ។

## មាត្រា ៧
## សេវាកម្មឯកសារ

១.ក្នុងព្រំដែនច្បាប់ជាតិរបស់ខ្លួនអនុញ្ញាត ភាគីទទួលសំណើត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពនូវសេវាកម្មឯកសារ ។

២.ក្នុងករណីសំណើសម្រាប់សេវាកម្មឯកសារកោះហៅសាក្សី ឬអ្នកជំនាញ ភាគីផ្ញើសំណើត្រូវបញ្ជូនឯកសារកោះហៅមកភាគីទទួលសំណើមិនតិចជាង ៩០ (កៅសិប) ថ្ងៃ មុនកាលបរិច្ឆេទនៃការមានវត្តមានរបស់សាក្សី ឬអ្នកជំនាញនៅលើដែនដីនៃភាគីផ្ញើសំណើ។ ក្នុងករណីបន្ទាន់ ភាគីទទួលសំណើអាចបោះបង់ការអនុវត្តអំឡុងពេលនេះ ។

៣.ភាគីទទួលសំណើ ត្រូវបញ្ជូនឯកសារដែលបានបញ្ជាក់អំពីកិច្ចដែលបានធ្វើសេវាកម្មឯកសារទៅភាគីផ្ញើសំណើ។ ប្រសិនបើសេវាកម្មឯកសារមិនអាចអនុវត្តបាន ភាគីផ្ញើសំណើត្រូវទទួលបានដំណឹងអំពីមូលហេតុនេះ។

## មាត្រា ៨
## ការផ្តល់ព័ត៌មាន

១.ភាគីទទួលសំណើត្រូវផ្តល់ច្បាប់ចម្លងនៃឯកសារ កំណត់ហេតុ ឬព័ត៌មានទាក់ទងនឹងជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ។

២.ភាគីទទួលសំណើអាចផ្តល់ច្បាប់ចម្លងនៃឯកសារ កំណត់ហេតុ ឬព័ត៌មានក្នុងទម្រង់ និងលក្ខខណ្ឌដូចគ្នា ដូចដែលបានផ្តល់ឲ្យដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ។

៣.ប្រសិនបើភាគីផ្ញើសំណើទាមទារសុំឯកសារច្បាប់ដើម ភាគីទទួលសំណើអាចផ្តល់ឯកសារច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារច្បាប់ដើមដែលត្រូវបានបញ្ជាក់នីត្យានុកូលកម្មប្រសិនបើមិនអាចផ្តល់ឯកសារច្បាប់ដើមបានទេ ។



5 ﾑ

## មាត្រា ៩
## ការឆែកឆេរ និងការចាប់យក

ក្នុងព្រំដែនច្បាប់ជាតិរបស់ខ្លួនអនុញ្ញាត ភាគីទទួលសំណើអនុវត្តការឆែកឆេរលើខ្លួនប្រាណបុគ្គល ឬទីកន្លែងដើម្បីស្វែងរក និងចាប់យកសម្ភារក្នុងរឿងក្តីព្រហ្មទណ្ឌដែលកើតឡើងនៅក្នុងដែនដីនៃភាគីធ្វើសំណើ។ ក្នុងករណីនេះ សិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់តតិយជន ត្រូវបានគោរព និងការពារ ។

## មាត្រា ១០
## ការប្រគល់មកវិញនូវសម្ភារដល់ភាគីទទួលសំណើ

១.តាមសំណើរបស់ភាគីទទួលសំណើ ភាគីធ្វើសំណើ ត្រូវប្រគល់មកវិញនូវឯកសារកំណត់ហេតុ និង/ឬវត្ថុដែលបានផ្តល់ឲ្យតាមសន្ធិសញ្ញានេះ នៅពេលដែលឯកសារ កំណត់ហេតុនិង/ឬវត្ថុនោះ លែងចាំបាច់ចំពោះរឿងក្តីព្រហ្មទណ្ឌ ដូចមាននៅក្នុងសំណើសុំជំនួយ។

២.នៅពេលមានសំណើ ទោះបីក្នុងពេលណាក៏ដោយ ភាគីធ្វើសំណើ អាចប្រគល់ជាបណ្តោះអាសន្ននូវឯកសារ កំណត់ហេតុ និង/ឬវត្ថុដែលខ្លួនទទួលបានដោយផ្អែកលើសំណើសុំជំនួយតាមសន្ធិសញ្ញានេះមកភាគីទទួលសំណើវិញ ប្រសិនបើ ឯកសារ កំណត់ហេតុ និង/ឬវត្ថុទាំងនេះត្រូវការ សម្រាប់រឿងក្តីព្រហ្មទណ្ឌលើដែនដីនៃភាគីទទួលសំណើ។

## មាត្រា ១១
## ការប្រមូលភស្តុតាង និងការទទួលយកចម្លើយ

១.ប្រសិនបើមានសំណើសុំជំនួយ ហើយស្របតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើ ត្រូវទទួលយកចម្លើយជាកសិណសាក្សី ឬ អំណះអំណាងរបស់បុគ្គល ឬ ទាមទារឲ្យបុគ្គលនោះប្រគល់វត្ថុដែលជាវត្ថុតាងសម្រាប់បញ្ជូនទៅភាគីធ្វើសំណើ។

២.បុគ្គលដែលត្រូវបានកោះហៅឲ្យផ្តល់ភស្តុតាង ដោយភាគីទទួលសំណើតាមសំណើសុំជំនួយតាមបញ្ញត្តិនៃមាត្រានេះ អាចបដិសេធការផ្តល់ភស្តុតាង ក្នុងករណីណាមួយខាងក្រោម ៖

ក.ច្បាប់ជាតិនៃភាគីទទួលសំណើអនុញ្ញាត ឬតម្រូវឲ្យបុគ្គលនោះបដិសេធក្នុងការផ្តល់ភស្តុតាងនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា នៅពេលដែលនីតិវិធីត្រូវបានអនុវត្តលើដែនដីនៃភាគីទទួលសំណើ ឬ

ខ.ច្បាប់ជាតិនៃភាគីធ្វើសំណើអនុញ្ញាត ឬតម្រូវឲ្យបុគ្គលនោះបដិសេធការផ្តល់ភស្តុតាងក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា នៅពេលដែលនីតិវិធីត្រូវបានអនុវត្តលើដែនដីនៃភាគីធ្វើសំណើ។



S ✓

៣.ប្រសិនបើបុគ្គលស្ថិតនៅក្នុងដែនដីនៃភាគីទទួលសំណើ អះអាងថាច្បាប់របស់ភាគីធ្វើសំណើបញ្ញត្តអំពីសិទ្ធិ ឬកាតព្វកិច្ចបដិសេធការផ្តល់ភស្តុតាង អាជ្ញាធរកណ្តាលរបស់ភាគីធ្វើសំណើ ប្រសិនបើទទួលបានសំណើ ត្រូវផ្តល់លិខិតបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ ឬកាតព្វកិច្ចនោះមកអាជ្ញាធរកណ្តាលនៃភាគីទទួលសំណើ។ ក្នុងករណីគ្មានភស្តុតាងផ្ទុយទេ លិខិតបញ្ជាក់នោះត្រូវជាទឡ្ហីករណ៍គ្រប់គ្រាន់សម្រាប់បញ្ជាក់ពីអត្ថិភាពនៃសិទ្ធិនោះ។

៤.ក្នុងគោលបំណងនៃមាត្រានេះ ការប្រមូលនូវភស្តុតាង ត្រូវរាប់បញ្ចូលទាំងការប្រមូលឯកសារ កំណត់ហេតុ ឬសម្ភារផ្សេងទៀត ដែលទាក់ទងនឹងការប្រមូលនូវភស្តុតាង។

## មាត្រា១២
## ការផ្ទេរកិច្ចដំណើរនីតិវិធី

១.ភាគីម្ខាង អាចផ្តល់ទៅភាគីម្ខាងទៀតនូវព័ត៌មានដែលទាក់ទងនឹងកត្តារួមផ្សំនៃបទល្មើស ហើយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ភាគីទទួលព័ត៌មាន ដើម្បីភាគីនេះ អាចចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌក្នុងដែនដីរបស់ខ្លួន។

២.ភាគីទទួលសំណើ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីធ្វើសំណើអំពីចំណាត់ការដោយផ្អែកព័ត៌មានដែលបានផ្តល់ឱ្យ។

## មាត្រា ១៣
## ការផ្ទេរជាបណ្តោះអាសន្ននូវទណ្ឌិតដែលអនុវត្តទោសដាក់ពន្ធនាគារ ដើម្បីជួយដល់ការស៊ើបអង្កេត ឬផ្តល់ភស្តុតាង លើដែនដីនៃភាគីធ្វើសំណើ

១.តាមសំណើរបស់ភាគីធ្វើសំណើ ទណ្ឌិតដែលកំពុងអនុវត្តទោសដាក់ពន្ធនាគារនៅលើដែនដីនៃភាគីទទួលសំណើ អាចត្រូវបានផ្ទេរជាបណ្តោះអាសន្នទៅភាគីធ្វើសំណើ ដើម្បីជួយសម្រួលដល់ការស៊ើបអង្កេត ឬផ្តល់ភស្តុតាងនៅលើដែនដីនៃភាគីធ្វើសំណើ។

២.ភាគីទទួលសំណើ ផ្ទេរទណ្ឌិតដែលកំពុងអនុវត្តទោសដាក់ពន្ធនាគារទៅឲ្យភាគីធ្វើសំណើបានតែក្នុងករណី ៖

ក.ជននោះ ស្ម័គ្រចិត្តយល់ព្រមចំពោះការផ្ទេរ ដើម្បីជួយសម្រួលដល់ការស៊ើបអង្កេត ឬផ្តល់ភស្តុតាង និង

ខ.ភាគីធ្វើសំណើយល់ព្រមគោរពតាមលក្ខខណ្ឌជាក់លាក់ ដែលបានតម្រូវដោយភាគីទទួលសំណើពាក់ព័ន្ធនឹងការឃុំខ្លួន និងធានាសុវត្ថិភាពរបស់ជនដែលត្រូវបានផ្ទេរនោះ។

៣.នៅពេលភាគីទទួលសំណើជូនព័ត៌មានដល់ភាគីធ្វើសំណើ ថាលែងត្រូវការឃុំ



5       4

ខ្លួនជនដែលត្រូវបានផ្ទេរនោះទៀតហើយ ជននោះនឹងត្រូវបានផ្តល់សេរីភាព និងទទួលបាននូវការប្រព្រឹត្តចំពោះខ្លួន ដូចជនដែលបានចែងក្នុងមាត្រា ១៤ នៃសន្ធិសញ្ញានេះ។

៤.ជនដែលត្រូវបានផ្ទេរតាមបញ្ញត្តិនៃមាត្រានេះ នឹងត្រូវប្រគល់មកភាគីទទួលសំណើតាមវិធីដែលគូភាគីបានព្រមព្រៀងគ្នាភ្លាម ក្រោយពេលបានផ្តល់ភស្តុតាង ឬនៅកាលបរិច្ឆេទឱ្យបានឆាប់ជាងនេះ ប្រសិនបើវត្តមានរបស់ជននោះលែងមានភាពចាំបាច់។

៥.ថិរវេលាដែលផ្ទេរ និង ថិរវេលាដែលឃុំខ្លួនជននោះនៅក្នុងទឹកដីនៃភាគីធ្វើសំណើ ត្រូវបានរាប់បញ្ចូលទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារ។

## មាត្រា ១៤
## ការរៀបចំបុគ្គលផ្សេងដើម្បីជួយដល់ការស៊ើបអង្កេត ឬផ្តល់ភស្តុតាងក្នុងដែនដីនៃភាគីធ្វើសំណើ

១.តាមសំណើរបស់ភាគីធ្វើសំណើ ភាគីទទួលសំណើ អាចអញ្ជើញបុគ្គលដែលមិនមែនជាបុគ្គលដូចមានចែងក្នុងមាត្រា១៣នៃសន្ធិសញ្ញានេះ ទៅដែនដីនៃភាគីធ្វើសំណើដើម្បីជួយសម្រួលដល់ការស៊ើបអង្កេត ឬផ្តល់ភស្តុតាងក្នុងដែនដីនៃភាគីធ្វើសំណើ។

២.ប្រសិនបើយល់ស្របទៅនឹងវិធានការណ៍ធានាសុវត្ថិភាពបុគ្គលនោះ ក្រោមការធានាជាលាយលក្ខណ៍អក្សរដោយភាគីធ្វើសំណើ ភាគីទទួលសំណើត្រូវស្នើសុំបុគ្គលនោះដើម្បីជួយដល់ការស៊ើបអង្កេត ឬផ្តល់ភស្តុតាងក្នុងដែនដីនៃភាគីធ្វើសំណើ។ បុគ្គលនោះត្រូវទទួលបាននូវព័ត៌មានអំពីសុវត្ថិភាព ការស្នាក់នៅ ការធ្វើដំណើរ និងរាល់ការចំណាយ ឬប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលត្រូវបង់ឱ្យខ្លួនក្នុងដែនដីភាគីធ្វើសំណើ។ ភាគីទទួលសំណើ ត្រូវជូនព័ត៌មានដល់ភាគីធ្វើសំណើ អំពីការឆ្លើយតបរបស់បុគ្គលនោះ ប្រសិនបើបុគ្គលនោះយល់ព្រម ហើយត្រូវចាត់វិធានការចាំបាច់ដើម្បីអនុវត្តសំណើសុំជំនួយ ។

## មាត្រា១៥
## សុវត្ថិភាព

១.បុគ្គលដែលមានវត្តមាននៅក្នុងដែនដីនៃភាគីធ្វើសំណើដោយអនុលោមតាមសំណើ ដូចចែងក្នុងមាត្រា១៣ និងមាត្រា ១៤នៃសន្ធិសញ្ញានេះ នឹង ៖

ក.មិនត្រូវបានឃុំខ្លួន ចោទប្រកាន់ ផ្តន្ទាទោស ឬទទួលរងនូវការដាក់កំហិត ផ្សេងៗលើសេរីភាពបុគ្គលនៅក្នុងទឹកដីនៃភាគីធ្វើសំណើ ទាក់ទងទៅនឹងអំពើសកម្ម ឬអកម្ម ឬត្រូវបានដាក់ទោសពីបទល្មើសណាមួយដែលប្រឆាំងនឹងច្បាប់របស់ភាគីធ្វើសំណើ ដោយសារមានការ



5 ᒪ

ចោទថា បានប្រព្រឹត្ត ឬកំពុងប្រព្រឹត្តបទល្មើសនោះ មុនពេលជននោះចេញដំណើរពីរដ្ឋដែលជាភាគីទទួលសំណើ។

ខ.មិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងអំពើសកម្ម ឬអកម្មណាមួយរបស់បុគ្គលនោះ ដែលត្រូវបានចោទថា បានកើតឡើង ឬកំពុងកើតឡើង មុនពេលដែលបុគ្គលនោះចាកចេញពីដែនដីនៃភាគីទទួលសំណើ។

គ.មិនត្រូវផ្តល់កស្តុតាងនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ឬជួយក្នុងការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌណាមួយ ក្រៅពីបញ្ហាដែលបានលើកឡើងនៅក្នុងសំណើសុំជំនួយ ប្រសិនបើគ្មានការយល់ព្រមពីបុគ្គលនោះ។

២.កថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ឈប់ការអនុវត្ត ប្រសិនបើបុគ្គលនោះមានសេរីភាពក្នុងការចាកចេញពីដែនដីនៃភាគីផ្ញើសំណើ ប៉ុន្តែមិនចាកចេញ ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃជាប់ៗគ្នា គិតពីថ្ងៃដែលបុគ្គលនោះ ត្រូវបានជូនព័ត៌មានផ្លូវការជាលាយលក្ខណ៍អក្សរ ថាវត្តមានរបស់បុគ្គលនោះលែងចាំបាច់ ឬបានចាកចេញហើយ ហើយបានវិលត្រឡប់មកវិញដោយស្ម័គ្រចិត្ត។

៣.បុគ្គលដែលមិនយល់ព្រមជួយដល់ការស៊ើបអង្កេត ឬផ្តល់កស្តុតាងតាមបញ្ញត្តនៃមាត្រា ១៣ ឬ មាត្រា ១៤ នៃសន្ធិសញ្ញានេះ មិនត្រូវទទួលរងនូវទណ្ឌកម្ម ឬវិធានការបង្ខំណាមួយនៅក្នុងដែនដីនៃភាគីផ្ញើសំណើ ឬនៅក្នុងដែនដីនៃភាគីទទួលសំណើ។

៤.បុគ្គលដែលយល់ព្រមជួយដល់ការស៊ើបអង្កេត ឬផ្តល់កស្តុតាង តាមបញ្ញត្តនៃមាត្រា ១៣ ឬ មាត្រា ១៤ នៃសន្ធិសញ្ញានេះ មិនត្រូវបានចោទប្រកាន់ដោយសំអាងលើចម្លើយរបស់បុគ្គលនោះ លើកលែងតែបុគ្គលនោះផ្តល់សក្ខីកម្មក្លែង ។

## មាត្រា ១៦
## ទ្រព្យដែលជាផលនៃបទល្មើស ឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើស

១.តាមសំណើសុំជំនួយ ភាគីទទួលសំណើ ត្រូវពិនិត្យថាតើមាន ឬគ្មាន ទ្រព្យដែលជាផលនៃបទល្មើស និង/ឬឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងដែនដីរបស់ខ្លួន និងត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅភាគីផ្ញើសំណើអំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន។

២.ករណីរកឃើញទ្រព្យសង្ស័យថា ជាផលនៃបទល្មើស និង/ឬឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើស ភាគីទទួលសំណើត្រូវចាត់វិធានការ ដែលច្បាប់ជាតិរបស់ខ្លួនអនុញ្ញាត ដើម្បីគ្រប់គ្រង ឬរឹបអូសទ្រព្យដែលជាផលនៃបទល្មើស និង/ឬឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើស

ទាំងនោះ។ តាមការអនុញ្ញាតនៃច្បាប់ជាតិរបស់ខ្លួន ភាគីទទួលសំណើអាចប្រគល់ទ្រព្យដែលជាផលនៃបទល្មើស និង/ឬឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើសឲ្យទៅភាគីផ្ញើសំណើ។ ការប្រគល់ត្រលប់ទៅវិញនូវទ្រព្យដែលជាផលនៃបទល្មើស និង/ឬឧបករណ៍ មធ្យោបាយប្រព្រឹត្តបទល្មើសទាំងនោះ ត្រូវអនុវត្តនៅពេលដែលមានសេចក្តីសម្រេចស្ថាពររបស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចនៃភាគីផ្ញើសំណើ ។

៣.ក្នុងការអនុវត្តមាត្រានេះ សិទ្ធិស្របច្បាប់របស់តតិយជនសុចរិត នឹងត្រូវបានគោរព និងការពារតាមច្បាប់ជាតិនៃភាគីទទួលសំណើ។

៤.គោលបំណងនៃសន្ធិសញ្ញានេះ "ទ្រព្យដែលជាផលនៃបទល្មើស" មានន័យថាជាទ្រព្យដែលមានប្រភពមកពី ឬទទួលបានដោយផ្ទាល់ ឬដោយប្រយោលពីការប្រព្រឹត្តបទល្មើស និង "ឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស" មានន័យថាជាទ្រព្យដែលបានប្រើប្រាស់ កំពុងប្រើប្រាស់ ឬនឹងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

## មាត្រា ១៧
## សេវាឯកសារ និងការប្រមូលភស្តុតាង
## តាមរយៈមន្ត្រីការទូត ឬមន្ត្រីកុងស៊ុល

ភាគីណាមួយ អាចផ្តល់សេវាកម្មឯកសារ និងប្រមូលភស្តុតាងពីប្រជាពលរដ្ឋរបស់ខ្លួនដែលមានវត្តមានលើដែនដីនៃភាគីម្ខាងទៀត តាមរយៈបេសកកម្មការទូត ឬស្ថានកុងស៊ុលដែលតាំងនៅទីនោះ ប្រសិនបើមិនរំលោភបំពានច្បាប់ជាតិរបស់ភាគីម្ខាងទៀតនោះ និងគ្មានវិធានការបង្ខំណាមួយ ត្រូវបានអនុវត្ត។

## មាត្រា ១៨
## កិច្ចការពារការសម្ងាត់ និងការកម្រិតលើការប្រើប្រាស់

១.ភាគីទទួលសំណើ អាចសុំរក្សាការសម្ងាត់ចំពោះព័ត៌មាន ឬភស្តុតាងដែលផ្តល់ឱ្យ ឬប្រភពនៃព័ត៌មាន ឬភស្តុតាងទាំងនោះ។ ការទម្លាយ ឬប្រើប្រាស់ ត្រូវស្របទៅនឹងលក្ខខណ្ឌដែលបានតម្រូវ។

២.ភាគីផ្ញើសំណើ អាចស្នើសុំរក្សាការសម្ងាត់ចំពោះខ្លឹមសារនៃសំណើសុំជំនួយ និងឯកសារភ្ជាប់នឹងសំណើសុំជំនួយ។ ប្រសិនបើសំណើសុំជំនួយមិនអាចអនុវត្តបាន ដោយមិនបំពានលើតម្រូវការរក្សាការសម្ងាត់ នោះភាគីទទួលសំណើ ត្រូវជូនដំណឹងទៅភាគីផ្ញើសំណើមុនពេលអនុវត្តសំណើសុំជំនួយ។ ភាគីផ្ញើសំណើ ត្រូវកំណត់ថាតើសំណើសុំជំនួយ គួរត្រូវបានអនុវត្តទាំងស្រុង ឬផ្នែកខ្លះ។



5 6

៣.ភាគីផ្ញើសំណើ ត្រូវធានាថារាល់ព័ត៌មាន ឬភស្តុតាងដែលទទួលបាន ត្រូវបានការពារ មិនឲ្យមានការបាត់បង់ ការទទួលបានមិនស្របច្បាប់ ការប្រើប្រាស់ ការកែប្រែ និងការទម្លាយព័ត៌មាន ឬការប្រើប្រាស់មិនត្រឹមត្រូវ។

៤.ភាគីផ្ញើសំណើ មិនត្រូវប្រើប្រាស់ ឬទម្លាយព័ត៌មាន ឬភស្តុតាងដែលទទួលបានអនុលោមតាមសន្ធិសញ្ញានេះ ក្រៅអំពីគោលបំណងដែលមានចែងដាក់លាក់នៅក្នុងសំណើសុំជំនួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ភាគីទទួលសំណើជាមុន។

## មាត្រា ១៩
## លិខិតបញ្ជាក់ និងលិខិតយថាភូត

១.សំណើសុំជំនួយ ឯកសារភ្ជាប់មកជាមួយ ឯកសារឬសម្ភារផ្សេងទៀតដែលបានផ្តល់សម្រាប់ការឆ្លើយតបទៅនឹងសំណើសុំជំនួយ នឹងមិនតម្រូវឲ្យមានទម្រង់ណាមួយនៃលិខិតបញ្ជាក់ ឬលិខិតយថាភូត លើកលែងកថាខណ្ឌទី ២ នៃមាត្រានេះ ។

២.ក្នុងករណីដែល ភាគីទទួលសំណើ ឬភាគីផ្ញើសំណើ ទាមទារឱ្យមានការបញ្ជាក់អំពីយថាភូតភាពនៃឯកសារឬសម្ភារ នោះឯកសារឬសម្ភារទាំងនោះ នឹងត្រូវបញ្ជាក់ឱ្យបានត្រឹមត្រូវតាមបែបបទដែលមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ។

៣.ឯកសារ ឬសម្ភារ ត្រូវកំណត់ថាបានធ្វើយថាភូតតាមសន្ធិសញ្ញានេះ ប្រសិនបើឯកសារឬសម្ភារនោះត្រូវបានចុះហត្ថលេខាដោយមន្ត្រីនៃអាជ្ញាធរមានសមត្ថកិច្ច និងបោះត្រាផ្លូវការរបស់ស្ថាប័នមានសមត្ថកិច្ចតាមច្បាប់ជាតិនៃភាគីផ្ញើ។

## មាត្រា ២០
## ការតំណាង និងការចំណាយ

១. ភាគីទទួលសំណើ ត្រូវតំណាងឱ្យផលប្រយោជន៍របស់ភាគីផ្ញើសំណើក្នុងពេលអនុវត្តសំណើសុំជំនួយលើកលែងតែមានចែងផ្សេងក្នុងសន្ធិសញ្ញានេះ។

២.ភាគីទទួលសំណើ ត្រូវទទួលបន្ទុកចំណាយលើការអនុវត្តសំណើសុំជំនួយ លើកលែងតែការចំណាយខាងក្រោមដែលជាបន្ទុករបស់ភាគីផ្ញើសំណើ៖

ក.ចំណាយទាក់ទងនឹងការដឹកជញ្ជូនបុគ្គលទៅ ឬ មកពីដែនដីនៃភាគីទទួលសំណើ និងសោហ៊ុយ ប្រាក់ឧបត្ថម្ភជីវភាព ចំណាយផ្សេងដែលបុគ្គលត្រូវទទួលបាន ក្នុងខណៈដែលបុគ្គលនោះ មានវត្តមានលើដែនដីនៃភាគីផ្ញើសំណើ តាមសំណើសុំជំនួយ អនុលោមតាមបញ្ញត្តិនៃមាត្រា ១៣ និងមាត្រា ១៤ នៃសន្ធិសញ្ញានេះ ។

ខ.ចំណាយទាក់ទងដល់មន្ត្រីទទួលបន្ទុកដឹកជញ្ជូន ឬការពារ ។



ร ꟿ

គ.ចំណាយលើអ្នកជំនាញ។

ឃ.ចំណាយទាក់ទងនឹងការបកប្រែផ្ទាល់មាត់ បកប្រែភាសាជាឯកសារ និងការកត់ត្រាឯកសារ និងការប្រមូលកស្តុតាងដោយរូបភាព តាមរយៈវីដេអូខនហ្វឺរេន ឬមធ្យោបាយអេឡិចត្រូនិចផ្សេងៗ ពីដែនដីនៃភាគីទទួលសំណើទៅភាគីផ្ញើសំណើ។

ង.ចំណាយទាក់ទងទៅនឹងការទទួលមកវិញនូវទ្រព្យដែលជាផលនៃបទល្មើស

ច.ចំណាយលើសពីធម្មតា ដែលកើតមានក្នុងកំឡុងពេលអនុវត្តសំណើសុំជំនួយដូចដែលភាគីទទួលសំណើទាមទារ។

## មាត្រា ២១
## ភាពត្រូវគ្នាជាមួយការរៀបចំផ្សេងទៀត

សន្ធិសញ្ញានេះ មិនរារាំងភាគីមួយក្នុងការផ្តល់ជំនួយដល់ភាគីផ្សេង ដោយអនុលោមតាមសន្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងផ្សេងទៀត ដែលគូភាគីជាសមាជិកឡើយ។

## មាត្រា ២២
## ការពិគ្រោះយោបល់

នៅពេលមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគី អាជ្ញាធរកណ្តាលនៃគូភាគីត្រូវពិគ្រោះយោបល់គ្នា ដើម្បីជម្រុញការអនុវត្តសន្ធិសញ្ញានេះឲ្យមានប្រសិទ្ធិភាពខ្ពស់បំផុត។ អាជ្ញាធរកណ្តាលនៃគូភាគី អាចព្រមព្រៀងអំពីវិធានការអនុវត្ត ដែលអាចជាការចាំបាច់ដើម្បីសម្រួលដល់ការអនុវត្តសន្ធិសញ្ញានេះ។

## មាត្រា ២៣
## ដំណោះស្រាយវិវាទ

រាល់ការវែងគំនិតគ្នាដែលកើតចេញពីការបកស្រាយ ឬការអនុវត្តសន្ធិសញ្ញានេះ នឹងត្រូវដោះស្រាយតាមរយៈការពិគ្រោះយោបល់រវាងគូភាគី។

## មាត្រា ២៤
## ការចូលជាធរមាន និងការបញ្ចប់

១. សន្ធិសញ្ញានេះ៖

ក.ត្រូវផ្តល់សច្ចាប័ន និងចូលជាធរមាន នៅថ្ងៃទី ៣០ (សាមសិប) គិតពីថ្ងៃទទួល



5 6

បានការជូនដំណឹងចុងក្រោយតាមរយៈបណ្តាញការទូត អំពីការបំពេញនីតិវិធីនៃការផ្តល់សច្ចាប័នត្រូវបានបំពេញចប់សព្វគ្រប់ ។

ខ.ត្រូវអនុវត្តចំពោះសំណើសុំជំនួយដែលបានធ្វើបន្ទាប់ពីការចូលជាធរមាន ទោះបីជាអំពើសកម្ម ឬអកម្ម បានកើតឡើងមុនពេលដែលសន្ធិសញ្ញានេះចូលជាធរមាន ។

គ.អាចត្រូវបានធ្វើវិសោធនកម្ម ដោយផ្អែកលើការយល់ព្រមជាលាយលក្ខណ៍អក្សររបស់គូភាគី។ វិសោធនកម្មនេះ ជាផ្នែកមួយដែលមិនអាចផ្តាច់ចេញពីសន្ធិសញ្ញានេះ។

២.ភាគី អាចបញ្ចប់សន្ធិសញ្ញានេះ តាមការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត។ ការបញ្ចប់សន្ធិសញ្ញានេះ មានអានុភាពក្រោយរយៈពេល ៦ (ប្រាំមួយ) ខែ គិតពីថ្ងៃទទួលបានដំណឹងរបស់ភាគីម្ខាង អំពីការបញ្ចប់សន្ធិសញ្ញានេះ។

៣.ក្នុងករណីដែលសន្ធិសញ្ញានេះបានបញ្ចប់អានុភាព សន្ធិសញ្ញានេះនឹងត្រូវបន្តការអនុវត្តចំពោះសំណើសុំជំនួយ ដែលបានធ្វើមុនពេលបញ្ចប់អានុភាពនៃសន្ធិសញ្ញានេះ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ។

ធ្វើនៅរដ្ឋធានីហាណូយ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៦ ធ្វើឡើងជា២ (ពីរ) ច្បាប់ ដែលមួយច្បាប់មានភាសាខ្មែរ ភាសាវៀតណាម និងភាសាអង់គ្លេស ដែលអត្ថបទនីមួយៗមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

**តំណាងព្រះរាជាណាចក្រកម្ពុជា** | **តំណាងសាធារណរដ្ឋសង្គមនិយមវៀតណាម**

**អង្គ វង្ស វឌ្ឍនា**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ឡេ មិញ ជី**
**អគ្គរដ្ឋអាជ្ញាប្រជាជនកំពូល**